វ៉ុល៣, លេខ៩, ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២១

# ការចោទប្រកាន់របស់សហរដ្ឋអាមេរិក លើមូលដ្ឋានកងទ័ពជើងទឹករាមៈ លេសនៃសង្គ្រាមត្រជាក់ថ្មី

អ៊ុន ឃាង *

កាលពី២ឆ្នាំមុន រដ្ឋាភិបាលសហរដ្ឋអាមេរិក បានចោទប្រកាន់ថា កម្ពុជាបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងសម្ងាត់មួយ ដែលអនុញ្ញាតឱ្យចិនដាក់កងទ័ពរបស់ខ្លួននៅឯមូលដ្ឋានកងទ័ពជើងទឹករាម។ រដ្ឋាភិបាលកម្ពុជា បានបដិសេធយ៉ាងដាច់អហង្ការ ចំពោះការចោទប្រកាន់ទាំងនោះ។ ថ្មីៗនេះកាលពីសប្តាហ៍មុន ការចោទប្រកាន់នេះ បានលេចឡើងសាជាថ្មី នៅពេលដែលអនុរដ្ឋមន្ត្រីការបរទេសសហរដ្ឋអាមេរិក លោកស្រី Wendy Sherman បានលើកឡើងពីបញ្ហានេះជាមួយលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន និងបានស្នើសុំការអនុញ្ញាតឱ្យមន្ត្រីការទូតអាមេរិកធ្វើទស្សនកិច្ចនៅទីតាំងនោះ។ ក្រោយមក សហរដ្ឋអាមេរិក បានបង្ហាញពីការមិនពេញចិត្តចំពោះដំណើរទស្សនកិច្ចរបស់អនុព័ន្ធយោធារបស់ខ្លួនទៅកាន់មូលដ្ឋានទ័ពជើងទឹករាម ដោយបានអះអាងថា យោធាកម្ពុជាមិនបានបើកឱ្យអនុព័ន្ធយោធារបស់ខ្លួនមើលបានពេញលេញនោះឡើយ។ លោកស្រី Sherman បានព្រមានថា ការបដិសេធរបស់កម្ពុជាចំពោះការធ្វើអធិការកិច្ចពេញលេញដោយសហរដ្ឋអាមេរិក នឹងបង្កជាផលប៉ះពាល់ដល់ទំនាក់ទំនងអាមេរិក-កម្ពុជា។ តើហេតុផលអ្វីខ្លះជាមូលដ្ឋាននៃការចោទប្រកាន់ និងការគំរាមកំហែងបែបនេះ? តើការទាមទាររបស់សហរដ្ឋអាមេរិកឱ្យមានការត្រួតពិនិត្យពេញលេញនោះ ត្រឹមត្រូវស្របទៅតាមច្បាប់អន្តរជាតិដែរឬទេ?

អត្ថបទកាសែត The Jakarta Post ចុះថ្ងៃទី២ ខែមិថុនា ឆ្នាំ២០២១ បានរាយការណ៍ថា ក្នុងជំនួបជាមួយ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន លោកស្រីអនុរដ្ឋមន្ត្រី Sherman “បានសួរថា តើកម្ពុជាអាចអនុញ្ញាតឱ្យអនុព័ន្ធយោធាពីស្ថានទូតអាមេរិក ធ្វើទស្សនកិច្ចទៅកាន់ទីតាំង ដែលត្រូវបានចោទប្រកាន់នេះបានឬទេ?”[1] លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានឆ្លើយតបជាវិជ្ជមាន ហើយក្រសួងការពារជាតិកម្ពុជាក៏បានរៀបចំដំណើរទស្សនកិច្ចនេះភ្លាមៗ។ វាគឺជារឿងគួរឱ្យហួសចិត្តមួយ ដែលសហរដ្ឋអាមេរិកបានចោទសួរពីភាពស្មោះត្រង់របស់រដ្ឋាភិបាលកម្ពុជា។ ក្នុងនាមជាអ្នកការទូតដែលមានបទពិសោធន៍មួយរូប លោកស្រី Sherman គួរតែបានដឹងយ៉ាងច្បាស់ណាស់ថា ការផ្តល់ដំណើរទស្សនកិច្ច

[1] សូមមើល The Jakarta Post. “US requests Cambodia for a visit to alleged’s China military base”. 2 June, 2021, https://www.thejakartapost.com/seasia/2021/06/02/us-requests-cambodia-for-a-visit-to-alleged-chinas-military-base.html។

*បណ្ឌិត អ៊ុន ឃាង គឺជាសាស្ត្រាចារ្យផ្នែកវិទ្យាសាស្ត្រនយោបាយ នៅសាកលវិទ្យាល័យ Northern Illinois សហរដ្ឋអាមេរិក និងជាសមាជិកក្រុមប្រឹក្សាភិបាលនៃមជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា។

មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា
Cambodia Development Center

© រក្សាសិទ្ធិដោយ មអក | ខ្លឹមសារនៃអត្ថបទនេះគឺជាគំនិតរបស់អ្នកនិពន្ធផ្ទាល់ និងមិនឆ្លុះបញ្ចាំងអំពីទស្សនៈរបស់មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា។

ទៅកាន់មូលដ្ឋានទ័ពនេះ មិនមែនមានន័យថា ជាការចុះត្រួតពិនិត្យទីតាំងដោយគ្មានលក្ខខណ្ឌនោះទេ។ កម្ពុជាក្នុងនាមជារដ្ឋអធិបតេយ្យមួយ ក៏ដូចជារដ្ឋដទៃទៀត រួមទាំងសហរដ្ឋអាមេរិកខ្លួនឯងផងដែរ ក្នុងហេតុផលសន្តិសុខជាតិប្រាកដជាមិនអាចអនុញ្ញាតឱ្យបរទេសណាមួយ មកធ្វើការត្រួតពិនិត្យមូលដ្ឋានយោធារបស់ខ្លួន ដោយគ្មានលក្ខខណ្ឌនោះឡើយ។

បន្ទាប់ពីជ័យជំនះរបស់ខ្លួននៅក្នុងសង្គ្រាមត្រជាក់ សហរដ្ឋអាមេរិក មិនបាននឹកស្រមៃថា នឹងត្រូវប្រឈមមុខនឹងចិនដែលឥទ្ធិពលកំពុងតែកើនឡើង ជាមួយការប្ដេជ្ញាចិត្ត និងសមត្ថភាព ក្នុងការស្តារមុខមាត់ និងឋានៈរបស់ខ្លួន នៅក្នុងប្រព័ន្ធអន្តរជាតិនោះឡើយ។ ដូច្នេះ សហរដ្ឋអាមេរិក បានចាត់ទុកប្រទេសចិន ថាជាអ្នកបំពានច្បាប់ (Rouge Actor)។ ក្នុងបរិបទនេះ វាច្បាស់ណាស់ថា ការមិនពេញចិត្តរបស់សហរដ្ឋអាមេរិក ទៅលើការបដិសេធរបស់កម្ពុជាចំពោះការធ្វើអធិការកិច្ចដោយឥតលក្ខខណ្ឌលើមូលដ្ឋានទ័ពជើងទឹករាម មានគោលបំណងទូលំទូលាយជាងអ្វីដែលគេមើលឃើញ ដែលផ្សារភ្ជាប់ជាមួយនឹងយុទ្ធសាស្ត្រភូមិសាស្ត្រនយោបាយរបស់សហរដ្ឋអាមេរិក ក្នុងការខ្ទប់ឥទ្ធិពលរបស់ចិន។ ការចោទប្រកាន់ថា កម្ពុជាអនុញ្ញាតឱ្យប្រទេសចិនសាងសង់មូលដ្ឋានទ័ពជើងទឹក គឺជារបៀបដែលសហរដ្ឋអាមេរិក ផ្ញើសារដល់ប្រទេសដទៃទៀត ដើម្បីបង្ការពួកគេពីការបង្កើតទំនាក់ទំនងជិតស្និទ្ធជាមួយប្រទេសចិន។ វាគឺជាយុទ្ធវិធីមួយ ផ្អែកលើសតិអារម្មណ៍នៃសង្គ្រាមត្រជាក់ ដែលលើកឡើងថា "មិត្តរបស់សត្រូវរបស់ខ្ញុំ គឺជាសត្រូវរបស់ខ្ញុំ"។ មានករណីពីមុនៗ ដែលយុទ្ធវិធីគំរាមចោទប្រកាន់របស់សហរដ្ឋអាមេរិក បានបង្កជាផលវិបាកយ៉ាងធ្ងន់ធ្ងរនៅពេលត្រូវបានប្រើប្រាស់ ដើម្បីសម្រេចនូវគោលដៅភូមិសាស្ត្រនយោបាយ និងមនោគមវិជ្ជារបស់ខ្លួន។

ពិភពលោកទាំងមូល គួរតែរំឭកខ្លួនឯង ពីការចោទប្រកាន់របស់សហរដ្ឋអាមេរិក ដែលថា អ៊ីរ៉ាក់មានអាវុធប្រល័យលោកនៅក្នុងឆ្នាំ២០០០។ ដោយលើកឡើងពីការបដិសេធមិនព្រមសហការរបស់អ៊ីរ៉ាក់ ជាមួយការទាមទារធ្វើការបញ្ជាក់អះអាងពីអាមេរិកនាពេលនោះ សហរដ្ឋអាមេរិក បានប្រឌិតភស្តុតាងនៃអាវុធប្រល័យលោករបស់អ៊ីរ៉ាក់ និងបានឈ្លានពានអ៊ីរ៉ាក់ជាហេតុធ្វើឱ្យប្រទេសនេះ ធ្លាក់ចូលទៅក្នុងភាពវឹកវរ ដែលរហូតមកដល់ពេលនេះ នៅមិនទាន់អាចស្តារឡើងវិញនៅឡើយ។ ដូចដែលអ្នកប្រាជ្ញជនជាតិអាមេរិកដ៏ល្បីល្បាញមួយរូប លោក John Mearsheimer បានអះអាងថា ការឈ្លានពានអ៊ីរ៉ាក់មិនមែនដោយសារអាវុធប្រល័យលោកនោះទេ ដែលសហរដ្ឋអាមេរិកខ្លួនឯង ក៏បានដឹងដូចគ្នាដែរថា អ៊ីរ៉ាក់មិនមានអាវុធប្រល័យលោកឡើយ។ ផ្ទុយទៅវិញ វាគឺជាលេសដើម្បីនាំយកមនោគមវិជ្ជាសេរី តួយ៉ាងប្រជាធិបតេយ្យលោកខាងលិច ទៅអ៊ីរ៉ាក់ និងមជ្ឈិមបូព៌ា។[2]

ប្រសិនបើសហរដ្ឋអាមេរិក មិនរៀនសូត្រពីប្រវត្តិសាស្ត្រទេនោះកម្ពុជាអាចប្រឈមនឹងស្ថានការណ៍ដូចគ្នាទៅនឹងអ៊ីរ៉ាក់។ យើងសង្ឃឹមថា ការណ៍នេះនឹងមិនកើតឡើងជាដាច់ខាត។ សហរដ្ឋអាមេរិកអាចប្រើលេសថាមានវត្តមានយោធាចិននៅកម្ពុជា ដើម្បីដាក់ទណ្ឌកម្មកម្ពុជាចំពោះភាពជិតស្និទ្ធជាមួយចិន។ ចំពោះសហរដ្ឋអាមេរិក ការចោទប្រកាន់ និងការគំរាមកំហែងនានា មកលើកម្ពុជា គឺជាការព្រមានដល់ប្រទេសដទៃទៀត ទាំងក្នុងតំបន់អាស៊ី និងលើសពីនេះ ថាបើពួកគេមិននៅខាងអាមេរិកទេ នោះពួកគេគឺជាសត្រូវរបស់អាមេរិក។

[2] សូមមើល John Mearsheimer, *Great Delusion: Liberal Dreams and International Realities*. Yale University Press, 2018។

ប្រទេសកម្ពុជា ធ្លាប់ជាប្រទេសរងគ្រោះពីគោលនយោបាយបិទខ្ទប់លិទ្ធិកុម្មុយនីស្តរបស់សហរដ្ឋអាមេរិក។ ស្លាកស្នាមដែលបន្សល់ពីភាពអន្តរាយនៃគោលនយោបាយបិទខ្ទប់របស់សហរដ្ឋអាមេរិក (Containment Policy) នៅតែត្រូវបានមើលឃើញយ៉ាងច្បាស់នៅប្រទេសកម្ពុជា។ ត្រង់ចំណុចនេះកង្វល់របស់កម្ពុជា គឺជាការព្រួយបារម្ភដ៏សមស្របមួយ ដែលកើតចេញពីការចោទប្រកាន់របស់សហរដ្ឋអាមេរិកលើករណីដែលបានលើកឡើងលើមូលដ្ឋានទ័ពជើងទឹករាម។ ចាប់តាំងពីឆ្នាំ១៩៩៣ កម្ពុជាបានទទួលផលប្រយោជន៍ពីទំនាក់ទំនងដ៏ល្អ ជាមួយគ្រប់ប្រទេសទាំងអស់។ ហេតុនេះ កម្ពុជាមានបំណងរក្សាទំនាក់ទំនងបែបនេះ ដោយឈរលើគោលការណ៍អធិបតេយ្យភាពជាតិ និងផលប្រយោជន៍ទៅវិញទៅមក។ គោលការណ៍នៃគោលនយោបាយការបរទេសរបស់កម្ពុជាបានបញ្ជាក់ថា កម្ពុជា៖

> ស្វាគមន៍ និងគាំទ្រនូវរាល់គំនិតផ្តួចផ្តើមទាំងឡាយណាដែលលើកកម្ពស់សន្តិភាព ស្ថិរភាព និងវិបុលភាពក្នុងតំបន់ និងផ្តោតលើកិច្ចសហប្រតិបត្តិការដែលផ្តល់ផលប្រយោជន៍រួមគ្នា និងបំពេញឱ្យគ្នាទៅវិញទៅមក។ ដូច្នេះ វាមានសារៈសំខាន់ និងភាពចាំបាច់ ក្នុងការកសាងភាពស៊ីសង្វាក់គ្នា និងការបំពេញឱ្យគ្នាទៅវិញទៅមកលើគំនិតផ្តួចផ្តើមតំបន់នានា រួមមាន «ខ្សែក្រវាត់និងផ្លូវ» «យុទ្ធសាស្ត្រឥណ្ឌូប៉ាស៊ីហ្វិក» និងគោលនយោបាយរបស់ប្រទេសធំៗក្នុងតំបន់ ដែលសម្លឹងមកតំបន់អាស៊ីអាគ្នេយ៍ ក៏ដូចជាកិច្ចសហប្រតិបត្តិការនានាក្នុងក្របខណ្ឌទន្លេមេគង្គ។[3]

ជាចុងក្រោយ កម្ពុជាសង្ឃឹមថា សហរដ្ឋអាមេរិក នឹងមិនបន្តប្រើប្រាស់ការចោទប្រកាន់លើវត្តមានយោធារបស់ចិន ដើម្បីធ្វើឱ្យប៉ះពាល់ដល់ទំនាក់ទំនងទ្វេភាគីអាមេរិក-កម្ពុជា ក្នុងគោលបំណងសម្រាប់ខ្ទប់ឥទ្ធិពលរបស់ចិននោះឡើយ។

Cambodia Development Center
Cambodia Development Center (@cd.centerkh)
Cambodia Development Center
Cambodia Development Center (t.me/cdcenterkh)
Building E, University of Puthisastra, #55, Street 180-184, Sangkat Boeung Raing, Khan Daun Penh
info@cd-center.org | (+855) 10 950 456 www.cd-center.org

មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា
Cambodia Development Center

[3] សូមមើល ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ព្រះរាជាណាចក្រកម្ពុជា, "ទិសដៅការងារការបរទេសរបស់កម្ពុជា," ទាញយកតាមរយៈ៖https://www.mfaic.gov.kh/Page/2021-02-08-Cambodia-s-Foreign-Policy-Direction (ទាញយកនៅថ្ងៃទី១០ ខែមីនា ឆ្នាំ២០២១)។